




# ជីវិត និង ធម្មជាតិ

## ពង្រឹងសមត្ថភាពបន្សុាំ និងភាពធន់របស់សហគមន៍តាមជនបទ ដោយប្រើប្រាស់វិធីសាស្រ្តគ្រប់គ្រងទីជម្រាលខ្នាតតូច ទល់ការប្រែប្រួលអាកាសធាតុ ដើម្បីអោយសម្រេចសន្តិសុខស្បៀងប្រកបដោយនិរន្តរភាពនៅកម្ពុជា

### សាវតា និងបរិបទនៃការអភិវឌ្ឍន៍

ប្រទេសកម្ពុជា គឺជាប្រទេសមួយអាស្រ័យខ្លាំងលើវិស័យកសិកម្ម ដែលមានប្រជាជនភាគច្រើនគឺជាកសិករនៅតាមតំបន់ជនបទ។ ប្រទេសកម្ពុជាមានភាពងាយរងគ្រោះខ្លាំងទៅនឹងការប្រែប្រួលអាកាសធាតុ ហើយបច្ចុប្បន្ននេះ ប្រទេសកម្ពុជានៅមានសមត្ថភាពទាបនៅឡើយក្នុងការទប់ទល់នឹងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ។

យោងទៅលើ កម្មវិធីបន្សុាំថ្នាក់ជាតិរបស់ប្រទេសកម្ពុជា (NAPA) ការប្រែប្រួលអាកាសធាតុបង្ករការគំរាមកំហែងយ៉ាងខ្លាំងដល់វិស័យកសិកម្ម និងសន្តិសុខស្បៀង។ របាយការណ៍បានបង្ហាញថា ប្រទេសកម្ពុជាបានជួបប្រទះនឹងគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួតជាញឹកញាប់។ កសិករ គឺជាអ្នកដែលងាយរងគ្រោះបំផុត ដែលធ្វើអោយពួកគាត់រស់នៅក្នុងភាពលំបាក និងអត់ឃ្លាន។ របាយការណ៍ NAPA បង្ហាញថា ច្រើនជាង ៨០% នៃគ្រួសារកសិករជួបប្រទះនឹងការខ្វះខាតទឹកសម្រាប់កសិកម្ម និងមាន ៥៥% ទទួលផលប៉ះពាល់លើសុខភាព និងកង្វះទឹកស្អាត។ ផលិតកម្មស្រូវ គឺជាផលិតកម្មដែលចម្បងជាងគេនៅក្នុងវិស័យកសិកម្ម ហើយវិស័យនេះកំពុងតែប្រឈមនឹងហានិភ័យខ្ពស់នាពេលបច្ចុប្បន្ននេះ។ វាអាស្រ័យជាចម្បងទៅលើទឹក ដែលមានប្រភពពីរសំខាន់ៗ៖ ទឹកហូរពីទន្លេមេគង្គផ្នែកខាងលើ និងទឹកភ្លៀងនៅរដូវវស្សា។

ការប្រែប្រួលអាកាសធាតុ ធ្វើអោយការធ្លាក់ភ្លៀង និង បរិមាណទឹកភ្លៀងមានការផ្លាស់ប្តូរ។ ក្នុងចន្លោះឆ្នាំ ១៩៩៨ ដល់ឆ្នាំ ២០០២ ផលិតផលកសិកម្មដែលបានបាត់បង់ស្ទើរតែទាំងអស់ គឺបាត់បង់ដោយសារតែទឹកជំនន់។ ការបាត់បង់ផលិតកម្មស្រូវបង្ករឡើង ដោយសារទឹកជំនន់មាន ៧០% និងបង្ករដោយគ្រោះរាំងស្ងួតមាន ២០%។



ការផ្លាស់ប្តូរប្រព័ន្ធកសិកម្មបានធ្វើអោយកម្រិតនៃការបំផ្លាញព្រៃឈើ និងការទន្ទ្រានដីកសិកម្មមានការកើនឡើងនៅផ្នែកខាងលើទីជម្រាល ដែលធ្វើអោយថយចុះប្រព័ន្ធក្បេត្របរិស្ថាន ដូចជា សីតុណ្ហភាព គុណភាពទឹក និងការរក្សាទឹកទុក ការគ្រប់គ្រងការហូរច្រោះ គ្រោះទឹកជំនន់និងរាំងស្ងួតបង្ករផលប៉ះពាល់ខ្លាំងដល់កសិករដែលអាស្រ័យលើទឹកសម្រាប់ការរស់រានមានជីវិតរបស់ពួកគេ។

កសិកររាប់ពាន់អ្នកទូទាំងប្រទេស មិនទាន់បានត្រៀមខ្លួនជាស្រេចទល់នឹងវិបត្តិបណ្តាលពីការប្រែប្រួលអាកាសធាតុ និងមិនមានជំនាញ និងឧបករណ៍ដែលត្រូវការសម្រាប់គ្រប់គ្រងប្រព័ន្ធក្បេត្របរិស្ថានលក្ខណៈចម្រុះ។

សហគមន៍កសិករនឹងប្រឈមហានិភ័យនៃការខ្វះខាតស្បៀង ប្រសិនបើគ្មានការគ្រប់គ្រងទឹក និងដីអោយមាននិរន្តភាព នៅពេលដែលការប្រែប្រួលអាកាសធាតុកំពុងតែកើនឡើង។

ការប្រើប្រាស់យុទ្ធសាស្រ្ត ប្រព័ន្ធក្បេត្របរិស្ថាន/ទីជម្រាល ដើម្បីគ្រប់គ្រងធនធានដី និងទឹក គឺមានសារៈសំខាន់ចំពោះជីវិតរស់នៅ និងសន្តិសុខស្បៀងរបស់កសិករក្រីក្រនៅក្នុងប្រទេសកម្ពុជា។

### គោលបំណង និងយុទ្ធសាស្រ្តរបស់គម្រោង

គម្រោងមានគោលបំណងបង្កើនគុណភាពជីវិតរបស់កសិកររាប់ពាន់អ្នកនៅក្នុងតំបន់គោលដៅ។ គម្រោងនេះ នឹងចូលរួមជា មួយនឹងការប្រឹងប្រែងរបស់ប្រទេសកម្ពុជា ក្នុងការកាត់បន្ថយ និងបន្សុាំ នឹងការប្រែប្រួលអាកាសធាតុរបស់សហគមន៍នៅតាមជនបទ។

វិធីសាស្រ្តដោយមានការចូលរួម ដូចជា ផែនការគ្រប់គ្រងទីជម្រាលនៅក្នុងតំបន់គោលដៅរបស់គម្រោងទាំងអស់ ដោយមានការដាំដំណាំ និងដាំដើមឈើនៅតាមអូរ ស្ទឹង ទន្លេ និងតំបន់ព្រៃ ក៏ដូចជា ការសាងសង់អាងស្តុកទឹកខ្នាតតូច និងប្រព័ន្ធស្រោចស្រពផ្សេងៗទៀត។ តាមរយៈសាលាស្រែកសិករ បច្ចេកទេសកសិកម្មដែលធន់នឹងការប្រែប្រួលអាកាសធាតុ នឹងត្រូវបង្រៀនដល់កសិករ ដើម្បីអោយពួកគាត់បង្កើនសន្តិសុខស្បៀង និងកាត់បន្ថយភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ។

GLOBAL ENVIRONMENT FACILITY
INVESTING IN OUR PLANET

Food and Agriculture Organization of the United Nations



ស្ត្រីជាមេគ្រួសារ គឺកាន់តែងាយទទួលរងផលប៉ះពាល់ ពីការប្រែប្រួលអាកាសធាតុ គម្រោងនឹងផ្តល់ការគាំទ្រដល់ស្ត្រីទាំងនោះទប់ទល់នឹងការប្រែប្រួលអាកាសធាតុ តាមរយៈការបង្កើតជម្រើសនៃមុខរបរចិញ្ចឹមជីវិត និងផ្តល់ការបណ្តុះបណ្តាលស្តីពី ជំនាញបន្សាំនឹងការប្រែប្រួលអាកាសធាតុ។

តំបន់គោលដៅសាកល្បងរបស់គម្រោង គឺមានទិដ្ឋភាពការប្រើប្រាស់ដីតំបន់ព្រៃឈើ និងតំបន់ការពារ ផ្សេងៗគ្នា។ ទិដ្ឋភាពផ្សេងៗគ្នានេះ នឹងអនុញ្ញាតិអោយគម្រោងធ្វើការបង្ហាញការកែលម្អរការបន្សុំ និងចងក្រងមេរៀនដែលអាចត្រូវបានអនុវត្ត និងពង្រីកនៅថ្នាក់ជាតិ។ តំបន់គោលដៅរបស់គម្រោងគ្របដណ្តប់ផ្ទៃដីសរុប ៥៩ ៩៥៥ ហិចតា។

## លទ្ធផលរំពឹងទុករបស់គម្រោង

ដោយមានការសហការជាមួយក្រសួងបរិស្ថាន (MOE) អង្គការ FAO នឹងផ្តល់ជំនាញ និងអនុវត្តសកម្មភាព ដើម្បីអោយសម្រេចបានលទ្ធផលចំនួន ៥ ដូចខាងក្រោម៖

*លទ្ធផល ១៖ ការបន្សុំនឹងការប្រែប្រួលអាកាសធាតុ ត្រូវបានបញ្ចូលទៅក្នុងគោលនយោបាយនិងផែនការកសិកម្ម និងសន្តិសុខស្បៀងរបស់ជាតិ*

*លទ្ធផល ២៖ ការគ្រប់គ្រងចម្រុះទីជម្រាលខ្នាតតូច ដោយមានការចូលរួម ដែលកាត់បន្ថយផលប៉ះពាល់ពីអាកាសធាតុមកលើធនធានធម្មជាតិ និងកសិកម្ម*

*លទ្ធផល ៣៖ កសិកម្មដែលធន់នឹងអាកាសធាតុ នឹងត្រូវបានជម្រុញ អនុវត្តបង្ហាញ និងរក្សានិរន្តរភាពតាមរយៈសាលាស្រែកសិករ*

*លទ្ធផល ៤៖ ជម្រើសផ្សេងនៃមុខរបរចិញ្ចឹមជីវិតដែលធន់នឹងអាកាសធាតុ ដែលផ្តោតលើស្ត្រី ត្រូវបានអនុវត្តសាកល្បងនិងរក្សាឲ្យមាននិរន្តភាព*

*លទ្ធផល ៥៖ ការតាមដាន និងវាយតម្លៃ (M&E) និងការផ្សព្វផ្សាយព័ត៌មាន*

## អ្នកពាក់ព័ន្ធ និងអ្នកទទួលផលពីគម្រោង

គម្រោងមានរយៈពេល ៥ឆ្នាំ នឹងចូលរួមចំណែក ពង្រឹងសមត្ថភាពក្រសួង និងស្ថាប័នផ្សេងៗ ដែលធ្វើការងារពាក់ព័ន្ធនឹងគោលនយោបាយបន្សុំនឹងការប្រែប្រួលអាកាសធាតុ កសិកម្ម និងសន្តិសុខស្បៀង។ នៅថ្នាក់ជាតិនឹងមានគោលនយោបាយ និងការអនុវត្តដែលឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ និង សន្តិសុខស្បៀង។

នៅកម្រិតសហគមន៍ គម្រោងនឹងជួយកែលម្អជីវិតរស់នៅគ្រួសារកសិករយ៉ាងហោចណាស់ចំនួន ១ ៩៥៧ គ្រួសារ នៅក្នុងខេត្ត សៀមរាប កំពង់ធំ រតនគិរី និងព្រះវិហារ តាមរយៈការគ្រប់គ្រងទីជម្រាលខ្នាតតូច ប្រកបដោយនិរន្តភាព ក៏ដូចជា នាំមកនូវភាពធន់ និងការអនុវត្តការបន្សុំល្អៗ។

ក្រុមកសិករដែលមានស្រាប់ ដូចជា ក្រុមកសិករប្រើប្រាស់ទឹក គណៈកម្មាការគ្រប់គ្រងស្រះត្រីរបស់សហគមន៍ នឹងទទួលផលប្រយោជន៍ដោយផ្ទាល់ពីគម្រោងនេះ។

## ម្ចាស់ជំនួយ និងដៃគូរ

គម្រោងបានទទួលការឧបត្ថម្ភពី GEF ដែលមានថវិកាសរុប ចំនួន ៥.២ លានដុល្លាអាមេរិក។ ដោយសារគម្រោងចូលរួមចំណែកទៅនឹងកម្មវិធីបន្សុំរបស់រាជរដ្ឋាភិបាល (NAPA) ក្រសួងបរិស្ថានគឺជាដៃគូរចម្បងរបស់អង្គការ FAO ក្នុងការអនុវត្តគម្រោងនេះ។ អង្គការ FAO នឹងសហការយ៉ាងជិតស្និទ្ធិផងដែរជាមួយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំពោះរាល់សកម្មភាពទាក់ទងនឹងកសិកម្ម និង សហការជាមួយស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត ដើម្បីអោយគម្រោងអនុវត្តបានជោគជ័យ។

ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) គឺជាដៃគូរសហការ និងជាអ្នកផ្តល់ទុនបដិភាគក្នុងការអនុវត្តគម្រោង។ គម្រោងនេះនឹងបំពេញបន្ថែមទៅលើគម្រោង "កាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍកសិករក្រីក្រនៅតំបន់ជុំវិញបឹងទន្លេសាប" របស់ធនាគារអភិវឌ្ឍន៍អាស៊ី នៅក្នុងខេត្តចំនួន ៤ ជុំវិញបឹងទន្លេសាបក្នុងប្រទេសកម្ពុជា។

